# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី១
# លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៩៥ ឯអ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤
# សម្រាប់លោកស្រី ចាន់ ស៊ីម៉ូលី ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារព្រៃខ្មែរ
# ឃុំអណ្តូងស្លាយ និងឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
# អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៩៥ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោកស្រី ចាន់ ស៊ីម៉ូលី នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោកស្រី ចាន់ ស៊ីម៉ូលី ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៦

-យោងកំណត់បង្ហាញសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លេខាធិការដ្ឋានលេខ ០១៣-០៦-លជ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៦

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៦

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៨៣ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦

## សម្រេច

### ប្រការ១

ដោយលោកស្រី **ចាន់ ស៊ីម៉ូលី** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") បានកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានមួយចំនួន ហើយត្រូវធ្វើការកែលំអជាបន្តទៀតនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរួមលេខ ០៩៥ ឯអ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ ដែលបានផ្តល់ជូនអ្នកកាន់អាជ្ញាប័ណ្ណ ដោយបន្តអាណត្តិអាជ្ញាប័ណ្ណចំនួន ៣ឆ្នាំ ទៀត ។

### ប្រការ២

អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៦ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩៥ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩៥ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទី កន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៩៥ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯក សារអាជ្ញាប័ណ្ណលេខ ០៩៥ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មី ស្របតាម សេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# ឧបសម្ព័ន្ធទី២
# មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

## ក-មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

**រោងម៉ាស៊ីន**

១- ទីតាំងម៉ាស៊ីនភ្លើងរបស់អ្នកកាន់អាជ្ញាប័ណ្ណស្ថិតនៅភូមិព្រៃខ្មែរ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

**លក្ខណៈទូទៅនៃម៉ាស៊ីន**

២- អ្នកកាន់អាជ្ញាប័ណ្ណមានម៉ាស៊ីនភ្លើងចំនួន ០២គ្រឿង ដែលមានអានុភាពតំឡើងសរុប ៨៥ kVA :

- ម៉ាស៊ីនលេខ១ អានុភាព ៤៥ kVA
- ម៉ាស៊ីនលេខ២ អានុភាព ៤០ kVA

៣- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងដ្យេសែល ។

៤- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសំរេចអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ឧបសម្ព័ន្ធទី២នេះត្រូវធ្វើការកែសំរួល ដោយភ្ជាប់ជាមួយសេចក្តីសំរេចឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្មនោះ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។